ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី៩ លេខ៤៩ សប្តាហ៍ទី១ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៩

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៤៥ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក លី គឹមស៊ីក (LEE KEUM SIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅក្រុង សេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា លី សំណាង (LEE SAMNANG) ៤៦០៤

១៩-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៦៥ ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តមចំនួន ០៣ រូប នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤៦០៥

១៩-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៦៦ ស្តីពីការផ្ទេរ ឯកឧត្តម ឌុំ ម៉ុន្ទ័រ ពីឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី ៤៦០៦

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៦៧ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូន វរសេនីយ៍ឯក ហួត គឹមសាន នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៤៦០៧

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៦៨ ស្តីពីការប្រោសព្រះរាជទានចំពោះលោក សៀង ម៉េង នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៤៦០៨

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៦៩ ស្តីពីការតែងតាំងលោក សៀង ម៉េង ជា ឧកញ៉ា ៤៦០៩

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧០ ស្តីពីការប្រោសព្រះរាជទានចំពោះលោក ថា សីហា នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៤៦១០

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧១ ស្តីពីការតម្លើងឋានៈឯកឧត្តមបណ្ឌិតរដ្ឋ គិច សំណាង អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៤៦១១

២០-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧២ ស្តីពីការតែងតាំងឯកឧត្តម ខិន ស្វា ជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៦១២

២១-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៣ ស្តីពីការដាក់មន្ត្រីរាជការក្រសួងយុត្តិធម៌ឱ្យចូលនិវត្តន៍ ចំនួន ០៤ រូប ៤៦១៣

២១-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៤ ស្ដីពីការតែងតាំងមន្ត្រីរាជការក្រសួងយុត្តិធម៌ចំនួន ០៤ រូប ៤៦១៥
២៥-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៥ ស្ដីពីការផ្ទេរ លោក លី សុខលេខ ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងយុត្តិធម៌ ៤៦១៧
២៥-៦-២០០៩ -ព្រះរាជក្រឹត្យនស/រកត/០៦០៩/៦៧៦ ស្ដីពីការតែងតាំងឯកឧត្តម សៀង ឈុនគ្រី ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤៦១៨
២៥-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៧៧ ស្ដីពីការតែងតាំងទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ចំនួន ០២ រូប ៤៦១៩

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៦-៦-២០០៩ -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្ដីពីការប្រែក្លាយវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៤៦២០
៣០-៦-២០០៩ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៤៦៣៥
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្ដីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ៤៦៣៧
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៤២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៥ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៤៤
➪អនុក្រឹត្យលេខ ៩០៦ អនក្រ.តត មិនទាន់បានទទួល
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៧ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៤៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៨ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៤៨
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩០៩ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៥០
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១០ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៥២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១១ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៥៤
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១២ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៥៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៣ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៥៨

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៤ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៦០
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៥ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៦២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៦ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៦៤
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៧ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៦៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៨ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៦៨
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩១៩ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៧០
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២០ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៧២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២១ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៧៤
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២២ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៧៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៣ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៧៨
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៤ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៨០
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៥ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៨២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៦ អនក្រ.បក ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៦៨៤
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៧ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកគូលែន នៃខេត្តព្រះវិហារ ៤៦៨៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៨ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុករវៀង នៃខេត្តព្រះវិហារ ៤៦៨៨
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩២៩ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងព្រះវិហារ នៃខេត្តព្រះវិហារ ៤៦៩០
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៣០ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកជាំក្សាន្ត នៃខេត្តព្រះវិហារ ៤៦៩២
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៣១ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកឆែប នៃខេត្តព្រះវិហារ ៤៦៩៤
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៣២ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកជ័យសែន នៃខេត្តព្រះវិហារ ៤៦៩៦
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៣៣ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសង្គមថ្មី នៃខេត្តព្រះវិហារ ៤៦៩៨

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៣៤ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកត្បែង មានជ័យ នៃខេត្តព្រះវិហារ ៤៧០០

២.សេចក្តីសំរេច

៣០-៦-២០០៩ -សេចក្តីសំរេចលេខ ៤០ សសរ ស្តីពីការបន្ថែមភារកិច្ចជូនឧបនាយករដ្ឋមន្ត្រី ៤៧០២

៣.សារាចរណែនាំ

១៣-៧-២០០៩ -សារាចរណែនាំលេខ ១០ សរណន ស្តីពីការចូលរួមមរណទុក្ខសពលោកជំទាវ ញ៉ែម សឿន ជា ស៊ុម ៤៧០៣

III.ការងារបណ្តាក្រសួង

ធនាគារជាតិ នៃ កម្ពុជា

២៦-៦-២០០៩ -ប្រកាសលេខ ធ.៩.០៩-១៦៦ ប្រក ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងអាជីវករប្តូរប្រាក់ និង ដេញថ្លៃរូបិយប័ណ្ណ ៤៧០៤

២៦-៦-២០០៩ -ប្រកាសលេខ ធ.៩.០៩-១៦៧ ប្រក ស្តីពីការបង្កើតគណៈកម្មការរៀបចំទីផ្សារអន្តរធនាគារ និង ប្តូរប្រាក់ ៤៧០៧

២៦-៦-២០០៩ -ប្រកាសលេខ ធ.៩.០៩-១៦៨ ប្រក ស្តីពីការបង្កើតគណៈកម្មការប្រតិបត្តិ រៀបចំទីផ្សារ អន្តរធនាគារ និង ប្តូរប្រាក់ ៤៧០៩

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី គឹមស៊ិក** (LEE KEUM SIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៦៤ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **លី សំណាង** (LEE SAMNANG) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩.០៦.៦៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៩

លេខ : ៥៩៣ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្ត

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឯកឧត្តម សែម សារឿន

២-ឯកឧត្តម ហេង តារិទ្ធ

៣-ឯកឧត្តម ឈុន ប៊ុនលី

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.០៩០៦.៦៧២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦១៩ .ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរ ឯកឧត្តម ជុំ ម៉ុនរ៉ុង ពី ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុង ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព.រ.ល.០៩០៦.៦៧៣

លេខៈ ៦២៣ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូន វរសេនីយ៍ឯក **ហួត គឹមសាន** អត្តលេខ ០១៧៦៩៧ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៧២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

៣រ.ល.០៩០៦.៦៧៤.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក សៀង មឿង

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

៣រល.០៩០៦.៦៧៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦០៧ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក សៀង មឿង

ជា

ឧកញ៉ា

ចរល.០៩០៦.៦៧៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

លេខៈ ៦០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៧ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ិន ចិនកេង

នស/រកត/០៦០៩/៦៧០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក យ៉ា សីថា

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៩០៦.៦៧៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

លេខៈ ៦១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស់/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១៣ និងមាត្រា៣០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និង ការកែសម្រួលមាត្រា១១ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតម្លើងឋានៈ ឯកឧត្តម បណ្ឌិតរដ្ឋ តិច សំណាង អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៦.៦៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៧៤២ ច.ល
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ានិត

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ទិន ស្ទូរា ជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៦.៦៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦៦០ ច.ល
ហត្ថលេខាដើមច្បាប់ចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ / នស / ៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៥ / ៤០៣ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការដាក់ចៅក្រម និងព្រះរាជអាជ្ញាឱ្យចូលនិវត្តន៍
- បានទ្រង់យល់ស្ថានភាពចាំបាច់នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់គោលការណ៍នៃសមត្ថកិច្ចជាប់ចំណុង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់ឱ្យចូលនិវត្តន៍ ÷

១. ឯកឧត្តម **អ៊ុក វិធុន** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល

២. ឯកឧត្តម **ហង់រ៉ូ រ៉ាកេន** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍

៣. លោក **ខៀវ សាម៉េត** ប្រធានសាលាដំបូងខេត្តកណ្តាល និងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

៤. លោក ស៊ិន ឌីម ប្រធានសាលាដំបូងខេត្តព្រះសីហនុ និងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ຫ.ໜ.໐໙໐໖.໒໕໐

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦០៥ ច.ល

ដោយចម្លងចេញពីច្បាប់ដើមចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៩

រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

[illegible] ឌិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ / នស / ៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ស្ថានភាពចាំបាច់នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានទ្រង់យល់គោលការណ៍នៃសមត្ថកិច្ចជាប់ចំណង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដោយផ្អែកតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ÷

១. លោកជំទាវ **ជា លាង** ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ជំនួសឯកឧត្តម **អ៊ុក វិធុន** ដែលត្រូវបានចូលនិវត្តន៍

២. ឯកឧត្តម **អ៊ុក សាវុធ** ជាអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ជំនួសឯកឧត្តម **ហង់រ៉ូ រ៉ាកេន** ដែលត្រូវបានចូលនិវត្តន៍

៣. ឯកឧត្តម **គង់ ស្រីម** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជំនួសលោក **ខៀវ សាម៉េត** ដែលត្រូវបានចូលនិវត្តន៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤. លោក យ៉េត ចរិយា ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជំនួសលោក ស៊ិន ឌីម ដែលត្រូវបានចូលនិវត្តន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ០៩០៦. ៦៤៣

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦០៦ ច.ល

ថតចម្លងចែក

ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរ លោក លី សុខលេង ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុង ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងយុត្តិធម៌ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៩០៦.៦៩៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦៧៩ ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
[illegible] អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម សៀង ឈុនធី ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧ល.០៩០៦. ៦៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

លេខ: ៦៤២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សាក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ដូចមានរាយនាមខាងក្រោម៖

១-ឯកឧត្តម រស់ សុភ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២-លោកជំទាវ កៀង ធីសូថា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៦.៦៧៦

លេខៈ ៦៣០. ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ប៊ុនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រែក្លាយវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យរបស់ក្រសួងការពារជាតិមកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតម្លើងសាលាពេទ្យកងយោធពលខេមរភូមិន្ទ ទៅជាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ សរសេរកាត់ថា **វ.វ.ស.** ត្រូវបានសម្រេចប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងការពារជាតិ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២.-

ទ.ទ.ស. ជានិតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

ទ.ទ.ស. មានអាសយដ្ឋាននៅភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ទ.ទ.ស.**។

មាត្រា ៣.-

ទ.ទ.ស. មានភារកិច្ចដូចតទៅ ÷

-បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រវេជ្ជសាស្ត្រ ថ្នាក់វេជ្ជបណ្ឌិតទូទៅ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រទន្តវិទនសាស្ត្រ ថ្នាក់ទន្តបណ្ឌិតទូទៅ ថ្នាក់បរិញ្ញាបត្រផ្នែកឱសថ ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្ររង ផ្នែកគិលានុបដ្ឋាក ឆ្មបផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ ផ្នែកជំនួយវេជ្ជសាស្ត្រ និងកម្មវិធីសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន

-បណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា

-រៀបចំ និងដំណើរការការងារប្រឡងជ្រើសរើសសិស្ស និស្សិតជាកងទ័ពនិងស៊ីវិលឱ្យចូលរៀនវគ្គអាហាររូបករណ៍ និងវគ្គបង់ថ្លៃ

-ធ្វើវិក្រឹតការអ្នកបច្ចេកទេសស្របតាមសំណូមពរសេចក្តីត្រូវការរបស់ក្រសួងការពារជាតិ

-បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់មហាវិទ្យាល័យវេជ្ជសាស្ត្រ និងសម្រាប់សាលាថែទាំវេជ្ជសាស្ត្រ

-រៀបចំកម្មវិធីសិក្សាដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងដោយមានការឯកភាពពីក្រសួងការពារជាតិ

-រៀបចំស្រាវជ្រាវវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រទន្តវិទនសាស្ត្រ វិទ្យាសាស្ត្រថែទាំ

-សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាខ្មែរ និងភាសាបរទេស ស្របតាមតម្រូវការប្រើប្រាស់ និងសម្រាប់ផ្សព្វផ្សាយទូទៅ

-កសាងផែនការមូលដ្ឋានសម្ភារៈសម្រាប់ **ទ.ទ.ស.**

-គ្រប់គ្រងនាយទាហាន នាយទាហានរង បុគ្គលិក កម្មករ និស្សិត សិស្ស សាស្ត្រាចារ្យ វេជ្ជបណ្ឌិត និងទ្រព្យសម្បត្តិរបស់ **ទ.ទ.ស.**

-ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ធ្វើឱ្យកាន់តែល្អប្រសើរនូវការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស។

ជំពូកទី២

ការដឹកនាំនិងការគ្រប់គ្រង

ផ្នែកទី១

ក្រុមប្រឹក្សាភិបាល

មាត្រា ៤.-

ទ.ទ.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **ទ.ទ.ស.**។

មាត្រា ៥.-

៥.១. ក្រុមប្រឹក្សាភិបាល មានសមាជិក ០៧(ប្រាំពីរ) រូប ដែលមានសមាសភាពដូចតទៅ ÷

-តំណាងក្រសួងការពារជាតិ	ប្រធាន
-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
-តំណាងក្រសួងសុខាភិបាល	សមាជិក
-តំណាងក្រសួងអប់រំយុវជន និងកីឡា	សមាជិក
-នាយក **ទ.ទ.ស.**	សមាជិកស្ម័យប្រវត្តិ
-តំណាងបុគ្គលិក **ទ.ទ.ស.**	សមាជិកស្ម័យប្រវត្តិ។

៥.២. តំណាងបុគ្គលិក **ទ.ទ.ស.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **ទ.ទ.ស.** សម្រាប់អាណត្តិនីមួយៗ។

៥.៣. ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមិនមែនជាសមាជិកស្ម័យប្រវត្តិ ត្រូវបានតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តបានទៀតតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬស្ថាប័នដែលខ្លួនតំណាងឱ្យ។

មាត្រា ៦.-

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាល សេដ្ឋកិច្ច អប់រំ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថាពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិម ឬបទឧក្រិដ្ឋពីតុលាការឡើយ។

មាត្រា ៧.-

៧.១.ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

៧.២.ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅ ក្រុមប្រឹក្សាភិបាលដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសុខាភិបាល និងតំណាងដៃគូអភិវឌ្ឍចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

មាត្រា ៨.-

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំតម្រង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ **ទ.ទ.ស.**។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ ៖

-ពិនិត្យ និងសម្រេចលើគំរោងផែនការអភិវឌ្ឍនៃ **ទ.ទ.ស.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល

-ពិនិត្យនិងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ទ.ទ.ស.**

-ពិនិត្យនិងសម្រេចលើចំណូលនិងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ទ.ទ.ស.**

-ពិនិត្យនិងសម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

-កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ទ.ទ.ស.**

- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភសការដល់បុគ្គលិក **ទ.ទ.ស.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ

-សម្រេចលើក្របខណ្ឌចំនួនបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ទ.ទ.ស.**

-សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈដោយអនុវត្តតាមបទបញ្ញត្តិនៃលទ្ធកម្មសាធារណៈ

-កែសម្រួលបទបញ្ជាផ្ទៃក្នុង **ទ.ទ.ស.** ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬក្រសួងអាណាព្យាបាលទាំងពីរ

-វាយតម្លៃតាមចន្លោះពេលទៀងទាត់លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ទ.ទ.ស.** ហើយកំណត់នូវវិធានការកែតម្រូវ ដើម្បីអនុវត្ត។

មាត្រា ៩.-

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ១០.-

១០.១.ក្រុមប្រឹក្សាភិបាល ទ.ទ.ស. ត្រូវធ្វើការប្រជុំយ៉ាងតិច៣(បី)ខែម្តង តាមគំនិតផ្តួចផ្តើម និងការអញ្ជើញរបស់ប្រធានឬតាមការស្នើរបស់សមាជិក ២/៣ (ពីរភាគបី) ឡើងទៅឬតាមការស្នើសុំរបស់នាយក ទ.ទ.ស.។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការអង្គប្រជុំ១(មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០(ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២. ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនិងយកជាការបាន លុះត្រាមានសមាជិកវត្តមានចំនួនលើសពី ៥០(ហាសិប) ភាគរយនៃសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំ ចាត់ទុកជា ឧត្តមានុភាព ។

១០.៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ និងតំកល់ទុកនៅទីស្នាក់ការ ទ.ទ.ស. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០(ដប់)ថ្ងៃ ក្រោយពេលប្រជុំ។

១០.៤. ទ.ទ.ស. ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ÷

-កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ផែនការអភិវឌ្ឍរបស់ ទ.ទ.ស.

-គម្រោងថវិកាប្រចាំឆ្នាំ

-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥. ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលទទួលក្នុងរយៈពេលមិនឱ្យហួសពី១៥ (ដប់ប្រាំ)ថ្ងៃឡើយ។

ផ្នែកទី២

អង្គភាពប្រតិបត្តិ នៃវិទ្យាស្ថាន

មាត្រា ១១.-

វ.វ.ស. ត្រូវគ្រប់គ្រងដោយនាយកវិទ្យាស្ថានមួយរូប ដែលមានឋានៈស្មើអគ្គនាយក។ នាយក វ.វ.ស. មានតួនាទីជានាយកប្រតិបត្តិ។

មាត្រា ១២.-

១២.១.នាយក វ.វ.ស. មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រងនិងអនុវត្តការងារ ដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយក វ.វ.ស. មានភារកិច្ចដូចតទៅ ៖

-រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល

-រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ វ.វ.ស.ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច

-ធ្វើរបាយការណ៍គ្រប់គ្រង ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ

-ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់លើភារកិច្ចរបស់បណ្ណាការិយាល័យ និងអង្គភាពក្រោមឱវាទ

-បំពេញរាល់មុខតំណែងរបស់ វ.វ.ស. ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពវិធានស្តីពីការគ្រប់គ្រងបុគ្គលិក

-បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ វ.វ.ស. ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត។

១២.២. នាយក វ.វ.ស. ជាតំណាងរបស់វិទ្យាស្ថាន ក្នុងការទំនាក់ទំនងជាមួយតតិយជន។

១២.៣. នាយក វ.វ.ស.ត្រូវស្នើទៅក្រសួងការពារជាតិ សុំតែងតាំងនាយករងមួយរូប ឬច្រើនរូប មានឋានៈស្មើប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

ផ្នែកទី៣

បុគ្គលិករបស់ វ.ទ.ស.

មាត្រា ១៣.-

១៣.១. បុគ្គលិកអចិន្ត្រៃយ៍របស់ **វ.ទ.ស.** រួមមានមន្ត្រីក្របខណ្ឌមកពីក្រសួងការពារជាតិ និងមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងស្ថាប័នដទៃទៀត។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

១៣.២. **វ.ទ.ស.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត។ បុគ្គលិកទាំងនោះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ។

១៣.៣. បុគ្គលិក មន្ត្រីរាជការ **វ.ទ.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល។ បទបញ្ជាស្តីពីបុគ្គលិកនេះ មិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិកព្រមទាំងបែបបទនៃការទូទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

ផ្នែកទី៤

ទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន

មាត្រា ១៤.-

១៤.១. **វ.ទ.ស.** ទទួលដើមទុនដំបូងពីរដ្ឋជាដីធ្លីនិងអចលនវត្ថុ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធតាមបញ្ជីសារពើភណ្ឌចុងក្រោយ ដែលផ្ទៃដីមានប្រមាណ ៨០ ០០០ (ប៉ែតសិបពាន់) ម៉ែត្រក្រឡា ដែលមានអាសយដ្ឋានស្ថិតនៅភូមិព្រៃសណ្តែក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

១៤.២. **វ.ទ.ស.** អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការរបស់វិទ្យាស្ថាន ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

ផ្នែកទី៥

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់ ទ.ទ.ស.

មាត្រា ១៥.-

ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃ ទ.ទ.ស. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ។

មាត្រា ១៦.-

១៦.១. នាយក ទ.ទ.ស. ជាអាណាប័កដើមខ្សែរបស់វិទ្យាស្ថាន ហើយត្រូវមានភារកិច្ចដូចតទៅ ÷

-ពិនិត្យប្រាក់ និងទូទាត់ចំណូល

-ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

១៦.២.អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិឬអាចបង្កើតនូវរដ្ឋទេយ្យចំណូលឬបុរេប្រទានបាន ដោយ មានការព្រមព្រៀងពីគណនេយ្យករ ទ.ទ.ស. ។

មាត្រា ១៧.-

១៧.១. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់ ទ.ទ.ស. ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករនេះត្រូវតែងតាំងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះ ត្រូវទទួលខុសត្រូវចំពោះមុខនាយក ទ.ទ.ស. និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នក ពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ ។

១៧.២. គណនេយ្យករមានភារកិច្ចដូចតទៅ ÷

-ប្រមូលចំណូល

-បើកប្រាក់ចំណាយ

-ថែរក្សានិងចាត់ចែងប្រើប្រាស់នូវមូលនិធិនិងធនធានរបស់ ទ.ទ.ស.

-ថែរក្សាលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣. គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន ។

មាត្រា ១៨.-

១៨.១. ប្រភពធនធានរបស់ ទ.ទ.ស. រួមមាន ÷

-ធនធានដែលរដ្ឋផ្តល់ដល់ ទ.ទ.ស. នៅពេលផ្តើមបង្កើតដំបូង

-ឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ

-អំណោយ ជំនួយ និងអច្ច័យទានដែល ទ.ទ.ស. បានទទួល

-ប្រាក់ខ្ចីបុលដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ ទ.ទ.ស.

-ផលការងារ និងកម្រៃ នៃការផ្តល់សេវាផ្សេងៗដោយ ទ.ទ.ស.

-កម្រៃនៃទ្រព្យរបស់ ទ.ទ.ស. និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល

-កម្រៃដែលបានមកពីការបង់ថ្លៃសិក្សារបស់សិស្ស និស្សិត

-កម្រៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ ទ.ទ.ស.។

១៨.២. ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ ទ.ទ.ស. ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់ ទ.ទ.ស.។ ក្រុមប្រឹក្សាភិបាលរបស់ ទ.ទ.ស. ត្រូវកំណត់អំពីបែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ទាក់ទងដល់ទម្រង់បែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៨.៣. ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ទ.ទ.ស. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូលនិងចំណាយ។

១៨.៤. អនុលោមតាមមាត្រា ១៣ នៃអនុក្រឹត្យនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗនៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង ទ.ទ.ស. ជាបន្ទុកនៃថវិការដ្ឋ។

១៨.៥. ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឱ្យ ទ.ទ.ស. ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹកនិងថ្លៃភ្លើង។

១៨.៦.សោហ៊ុយវិភាគនិងសោហ៊ុយដំណើរការសម្រាប់ស្រាវជ្រាវវិភាគ សម្រាប់ពេលមានភាពអាសន្ន ត្រូវចែងក្នុងកិច្ចសន្យាមួយរវាងរដ្ឋ និង ទ.ទ.ស. ដែលមានបញ្ជាក់ចំណែកដែលម្ខាងៗត្រូវរ៉ាប់រង។

មាត្រា ១៩.-

១៩.១. ការងារគណនេយ្យរបស់ ទ.ទ.ស. រួមមាន ÷

-គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេរភាគដែលចែងអំពីប្រតិបត្តិការថវិការធនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន

-គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ

-គណនេយ្យវិភាគប្រសិនបើជាការចាំបាច់ ។

គណនេយ្យរបស់ ទ.ទ.ស. ត្រូវ ÷

-ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គោរពតាមប្លង់គណនេយ្យរបស់ ទ.ទ.ស.ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.២.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ទ.ទ.ស. ត្រូវរៀបចំដោយគណនេយ្យករ និងអាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាល ពិនិត្យនិងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣(បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

មាត្រា ២០.-

មូលនិធិរបស់ ទ.ទ.ស. គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនេយ្យមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្នែកទី៦

របបសារពើពន្ធនៃ ទ.ទ.ស.

មាត្រា ២១.-

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ ទ.ទ.ស. ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ។

ផ្នែកទី៧

លទ្ធកម្មរបស់ ទ.ទ.ស.

មាត្រា ២២.-

ការសម្រេចការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ ទ.ទ.ស.ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញត្តិជាធរមានទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានេះ។

ជំពូកទី៣

ផ្នែកទី១

អាណាព្យាបាលបច្ចេកទេស

មាត្រា ២៣.-

២៣.១. ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក **ទ.ទ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍនិងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល១(មួយ)ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃបានទទួលឯកសារដែលបានបញ្ជូនដោយនាយក **ទ.ទ.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ។

២៣.២. លិខិតយល់ព្រមត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងការពារជាតិឬតំណាង ហើយត្រូវផ្ញើជូនទៅនាយក **ទ.ទ.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយក **ទ.ទ.ស.** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍឬគម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងការពារជាតិ ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សានិងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ **ទ.ទ.ស.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ)បំណែក នៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ២៤.-

២៤.១ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចមានយោបល់ជំទាស់លើឯកសារ ដែលបានបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងការពារជាតិ មានរយៈពេល ១ (មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

២៤.២ នាយក ទ.ទ.ស. ត្រូវជូនព័ត៌មានដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។

មាត្រា ២៥.-

២៥.១. រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចលុបឬផ្អាកទុកនូវសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬនាយក ទ.ទ.ស. ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់វិទ្យាស្ថាន
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

២៥.២. ការលុបចោលឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួនឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក ទ.ទ.ស. ហើយនាយក ទ.ទ.ស.ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលយ៉ាងឆាប់បំផុត។

មាត្រា ២៦.-

រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងាររបស់ ទ.ទ.ស. ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងទប្បញ្ញត្តិជាធរមាន។

ផ្នែកទី២

អាណាព្យាបាលហិរញ្ញវត្ថុ

មាត្រា ២៧.-

២៧.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាលនាយក ទ.ទ.ស. ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ។ រដ្ឋមន្ត្រីក្រសួងការពារជាតិ មានរយៈពេល ១(មួយ)ខែ គឺចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល២(ពីរ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមក ដោយនាយក ទ.ទ.ស.ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៧.២.លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឬអ្នកតំណាង ត្រូវផ្ញើទៅនាយក ទ.ទ.ស. ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ។ នាយក ទ.ទ.ស.ត្រូវជូនព័ត៌មាននេះដល់ក្រុមប្រឹក្សាភិបាល យ៉ាងឆាប់បំផុត។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយក្នុងករណីដែលការជំទាស់ដែលលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ។

មាត្រា ២៨.-

សេចក្តីសម្រេចដូចបានរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាលឬនាយក ទ.ទ.ស.ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការពារជាតិ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

-សេចក្តីសម្រេចស្តីពីការលក់ ឬការផ្ទេរសិទ្ធិអចលនទ្រព្យ

-សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ។

សេចក្តីសម្រេចនេះត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិជាធរមាន។

មាត្រា ២៩.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ មួយរូបប្រចាំ ទ.ទ.ស.។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ទ.ទ.ស. ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មាត្រា ៣០.-

៣០.១. ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ ទ.ទ.ស. ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.២. ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាល នៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់អធិការកិច្ច ឬការត្រួតពិនិត្យលើ ទ.ទ.ស. នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន ។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា ៣១.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាប
ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
សូមហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ទៀ បាញ់

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
